ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សេចក្តីជូនព័ត៌មាន

កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ កាសែតភ្នំពេញប៉ុស្តិ៍ ជាភាសាខ្មែរ បានផ្សព្វផ្សាយនូវចំណងជើងថា "រដ្ឋាភិបាលបើកផ្លូវឲ្យជនបរទេស នាំទារកកើតដោយការពពោះជំនួសចេញពីកម្ពុជា" ហើយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ នេះដដែលនៅលើការផ្សាយរបស់សារព័ត៌មានខ្មែរអប្សរា (The Khmer Apsara) បានផ្សាយអត្ថបទដែលស្ទើរតែដកចេញទាំងស្រុងពីកាសែតភ្នំពេញប៉ុស្តិ៍ នឹងបានដាក់ចំណងជើងថា " សេវាស្ត្រីខ្មែរស៊ីឈ្នួលពពោះរស់វិញហើយ" ព្រមទាំងបានលើកក្នុងអត្ថបទខ្លួនថា " ជាថ្មីម្តងទៀត អាជីវកម្មពពោះ ត្រូវបានកាសែតចុះផ្សាយព្រោងព្រាត តែពុំមែនជារឿងរ៉ាវប៉ូលីសចាប់បានជនល្មើសពាក់ព័ន្ធ អាជីវកម្មពពោះជំនួស ស្អីនោះទេ គឺជាការផ្សាយដំណឹងល្អ ដែលអាជីវកម្មមួយនេះត្រូវបានអនុញ្ញាត" ដែលបង្កឲ្យមានការយល់ច្រលំនៅក្នុងមតិមហាជន។

ពាក់ព័ន្ធនិងការលើកឡើងនេះ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានកិត្តិយសសូមធ្វើការបំភ្លឺដូចតទៅៈ

១. រាជរដ្ឋាភិបាលកម្ពុជាមានគោលជំហរដាច់ខាត មិនអនុញ្ញាតឲ្យយកអំពើពពោះជំនួសជាអាជីវកម្មនោះទេ ។ ទង្វើកន្លងមក គឺបានកើតឡើងនៅក្នុងពេល ច្បាប់ពពោះជំនួសកំពុងតែរៀបចំ ហើយត្រូវការពិនិត្យពិច័យ ព្រោះការពពោះជំនួសនេះអាចចូលជាជាករណីរត់ពន្ធមនុស្ស ជួញដូរមនុស្ស និងជួញដូរសរីរាង្គ។

២. "កិច្ចប្រជុំផ្សព្វផ្សាយអំពី គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណីពពោះជំនួស ដើម្បីយកទៅចិញ្ចឹម នៅក្រៅប្រទេស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ដែលសមាសភាពចូលរួមក្នុងកិច្ចប្រជុំ មានថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ តំណាងអង្គទូតដែលមាននិវេសនដ្ឋាននៅកម្ពុជាចំនួន១៩ប្រទេស ព្រមទាំងភាគីពាក់ព័ន្ធជាច្រើនរូបទៀត ។ គឺជាដំណោះស្រាយ ក្នុងជំហានចំពោះមុខនៅពេលដែលច្បាប់ស្តីពីការពពោះជំនួសកំពុងរៀបចំ ដើម្បីធានាសុវត្ថិភាពទារក ដែលមានកំណើតនិងបានកើតហើយ ដាក់ឱសានវាទត្រឹម ខែមករា ឆ្នាំ២០១៨ តែប៉ុណ្ណោះ ។ ប្រសិនបើឪពុកដែលស្នើឲ្យមានការពពោះនោះ មិនព្រមចូលមកស្នើសុំយកកូនចេញតាមនិតិវិធីនេះទេ ការនាំទារក ឬកុមារចេញដោយខុសច្បាប់ នឹងត្រូវប្រឈមមុខនឹងច្បាប់ព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៣. ដូច្នេះ សូមសាធារណៈជន កុំមានការភ័ន្តច្រលំ ថារដ្ឋាភិបាលបើកផ្លូវ ចំពោះអំពើពពោះជំនួស ដើម្បីជាអាជីវកម្មលើជីវិតទារកនៅកម្ពុជាឲ្យសោះ។

ភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧